## របៀបទាក់ទង TIAS ៖

TIAS មានផ្តល់ជូន៖ ពីថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ ម៉ោង៩ព្រឹក - ម៉ោង៥ល្ងាច (លើកលែងតែថ្ងៃបុណ្យសាធារណៈ)។

សូមទាក់ទង TIAS តាមរយៈលេខទូរស័ព្ទឥតគិតថ្លៃ៖

# 1800 060 462

ទីប្រឹក្សាយោបល់ផ្នែកជួលទីលំនៅ ក៏នៅប្រចាំការផងដែរដើម្បីឆ្លើយសំណួរដោយផ្ទាល់ នៅតាមការិយាល័យសេវាស្វែងរកការងារធ្វើ Job Prospects ដែលបានជ្រើសតាំងមួយចំនួនតាមការណាត់ជួបតែប៉ុណ្ណោះ។

## ទីតាំង TIAS៖

ទីប្រឹក្សាយោបល់ផ្នែកជួលទីលំនៅ មាននៅប្រចាំការដើម្បីឆ្លើយសំណួរដោយផ្ទាល់ តាមការណាត់ជួបតែប៉ុណ្ណោះនៅតាមការិយាល័យសេវាស្វែងរកការងារធ្វើ Job Prospects ដែលបានជ្រើសតាំងមួយចំនួន នៅតំបន់៖

- តំបន់ប៉ែកខាងលិច
- តំបន់ប៉ែកខាងជើង
- តំបន់ប៉ែកខាងត្បូង
- តំបន់ជុំវិញក្រុង

ដើម្បីធ្វើការណាត់ជួប សូមទូរស័ព្ទលេខ **1800 060 462** ក្នុងអំឡុងពេលម៉ោងធ្វើការ។

សម្រាប់បញ្ជីទីតាំង TIAS បច្ចុប្បន្ន សូមបើកចូលវិបសាយ **www.tias.org.au**

ជំនួយអាទិភាពនឹងផ្តល់ជូនគ្រួសារទាំងឡាយ ដែលកំពុងបង់ថ្លៃឈ្នួលលើសពី៣០ភាគរយ នៃប្រាក់ចំណូលរបស់ខ្លួន។

SYCLtd SYCLtd hypa_syc SYC Limited

www.syc.net.au

Government of South Australia

SYC

Khmer / ខ្មែរ

# TIAS

TENANTS' INFORMATION & ADVISORY SERVICE

សេវាផ្តល់ព័ត៌មាន និងប្រឹក្សាយោបល់សម្រាប់អ្នកជួលទីលំនៅ



## ការផ្តល់ប្រឹក្សាយោបល់ និងជំនួយដល់អ្នកជួលទីលំនៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង។

TIAS គឺជាសេវាកម្មបម្រើទូទាំងរដ្ឋដែលផ្តល់ព័ត៌មាន ការប្រឹក្សាយោបល់ និងការគាំទ្រ ដោយឥតគិតថ្លៃ ហើយឯករាជ្យ ដើម្បីជួយប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប ដើម្បីទប់ទល់នឹងថ្លៃឈ្នួលក្នុងលំនៅដ្ឋានជួលឯកជន លំនៅដ្ឋានសហគមន៍ ឬលំនៅដ្ឋានសាធារណៈ។

**www.tias.org.au**

# តើ TIAS អាចផ្តល់អ្វីខ្លះ?

- ការអប់រំ ព័ត៌មាន និងការប្រឹក្សាយោបល់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក ក្នុងនាមជាអ្នកជួលទីលំនៅ
- តំណាង និងជំនួយផ្នែកសវនាការសាលាក្តីស៊ីវិល និងរដ្ឋបាលរដ្ឋអូស្ត្រាលីខាងត្បូង (SACAT)
- ការលើកទឹកចិត្ត និងជំនួយដើម្បីចូលរួមក្នុងដំណើរការសម្រុះសម្រួល និងជាមួយអ្នកផ្តល់សេវាលំនៅដ្ឋាន
- ជំនួយដើម្បីមានលទ្ធភាពទទួលបានជំនួយផ្ទៃក្នុង នៃបណ្តឹងឧទ្ធរណ៍ជាមួយអ្នកផ្តល់សេវាលំនៅដ្ឋានដែលពាក់ព័ន្ធ
- ការបញ្ជូន និងការផ្តល់ព័ត៌មានអំពីការប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុ និងសេវាផ្សេងទៀត ដែលពាក់ព័ន្ធនឹងស្ថានភាពរបស់អ្នក





# តើអ្នកមានសិទ្ធិទទួលបានជំនួយពី TIAS ឬទេ?

ជំនួយអាចផ្តល់ជូនគ្រួសារទាំងឡាយដែលមានប្រាក់ចំណូលទាប នៅក្នុង៖

- លំនៅដ្ឋានសាធារណៈ
- លំនៅដ្ឋានជួលឯកជន
- លំនៅដ្ឋានសហគមន៍
- លំនៅដ្ឋានសហករណ៍

ជំនួយអាទិភាពនឹងផ្តល់ជូនគ្រួសារទាំងឡាយ ដែលកំពុងបង់ថ្លៃឈ្នួលលើសពី៣០ភាគរយ នៃប្រាក់ចំណូលរបស់ខ្លួន។

ប្រសិនបើអ្នកមិនប្រាកដច្បាស់ថាតើអ្នកមានសិទ្ធិទទួលបានឬអត់ សូមបើកចូលវិបសាយ **www.tias.org.au** សម្រាប់ព័ត៌មានបន្ថែម។

# តើ TIAS ជួយដោះស្រាយបញ្ហាអ្វីខ្លះ?

TIAS អាចជួយដោះស្រាយបញ្ហាណាមួយដែលទាក់ទងនឹងការជួលទីលំនៅរបស់អ្នក ដូចជា៖

- កិច្ចសន្យាជួលទីលំនៅ
- ជម្លោះអំពីប្រាក់កក់
- ការថែទាំអចលនទ្រព្យ
- ដំណើរការ SACAT
- នីតិវិធី និងបណ្តឹងឧទ្ធរណ៍របស់ក្រសួងលំនៅដ្ឋាន Housing SA និងលំនៅដ្ឋានសហគមន៍
- ប្រាក់ជំពាក់ថ្លៃឈ្នួល

TIAS **មិនអាច**ផ្តល់ការគាំទ្រសម្រាប់អ្នកបានទេ ប៉ុន្តែនៅតែអាចមានលទ្ធភាពផ្តល់ជូនអ្នក នូវការប្រឹក្សាយោបល់ និងព័ត៌មានទូទៅ ប្រសិនបើអ្នក៖

- ជាអ្នកស្នាក់នៅក្នុងផ្ទះជួលមានផ្តល់ចំណីអាហារ ឬផ្ទះជួលមានបន្ទប់ច្រើន
- រស់នៅក្នុងការ៉ាវ៉ាន ឬលំនៅដ្ឋានតាមទីឧទ្យាន
- កំពុងស្វែងរកការស្នាក់នៅជាបន្ទាន់
- ជាស្ថាប័ន ឬអង្គភាព
- កំពុងមានបញ្ហាជម្លោះរវាងអ្នកជិតខាង និងអ្នកជិតខាង